DSHS WASHINGTON STATE Department of Social and Health Services

សន្លឹកព័ត៌មានអំពី
ការស៊ើបអង្កេតសេវាការពារមនុស្សពេញវ័យ **(APS)**
Adult Protective Services (APS) Investigations
Fact Sheet

សេវាការពារមនុស្សពេញវ័យ(APS) គឺកំពុងស៊ើបអង្កេតរបាយការណ៍មួយដែលអ្នកប្រហែលជាបានរំលោភបំពាន បោះបង់ចោល កេងប្រវ័ញ្ចផ្នែកហិរញ្ញវត្ថុ ឬមិនអើពើទីងមនុស្សពេញវ័យដែលងាយរងគ្រោះ។ ឯកសារនេះប្រាប់អ្នកអំពីដំណើរការស៊ើបអង្កេត សិទ្ធិរបស់អ្នក និងព័ត៌មានសំខាន់ៗផ្សេងទៀត។ ក្នុងនាមជាផ្នែកមួយនៃការស៊ើបអង្កេត(APS) ទីងពិនិត្យឯកសារ និងសម្ភាសន៍មនុស្សអំពីការចោទប្រកាន់។

លទ្ធផលនៃការស៊ើបអង្កេតអាចមានផលវិបាកធ្ងន់ធ្ងរសម្រាប់អ្នក។ សូមអានវាដោយប្រុងប្រយ័ត្ន។

អ្នកស៊ើបអង្កេតដែលត្រូវបានចាត់តាំងឲ្យទទួលបន្ទុកសំនុំរឿងរបស់អ្នកគឺ៖
ពួកគេអាចទៅដល់នៅ៖

តើខ្ញុំមានសិទ្ធិអ្វីខ្លះ?

• អ្នកមានសិទ្ធិមានភាគីទីបី (ដូចជាមិត្តភក្តិ មេធាវី តំណាងសហជីព សមាជិកគ្រួសារ ឬអាណាព្យាបាលនៅជាមួយអ្នកក្នុងពេលសម្ភាសន៍។

• ប្រសិនបើភាសាអង់គ្លេសមិនមែនជាភាសាចម្បងរបស់អ្នកទេ អ្នកមានសិទ្ធិទទួលបានអ្នកបកប្រែដោយឥតគិតថ្លៃ (APS មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សមាជិកគ្រួសារជាបកប្រែទេ)។

• អ្នកមានសិទ្ធិមិនចូលរួមក្នុងការសម្ភាសន៍ បញ្ឈប់ ឬកំណត់ពេលវេលាឡើងវិញ។

• អ្នកមានសិទ្ធិផ្តល់ជូន APS នូវឯកសារ ឬសាក្សីដែលទាក់ទងនឹងការចោទប្រកាន់។

តើ **APS** នឹងជូនដំណឹងមកខ្ញុំអំពីលទ្ធផលនៃការស៊ើបអង្កេតយ៉ាងដូចម្តេច?

• APS ធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាងដែល APS ប្រមូលបានក្នុងអំឡុងពេលស៊ើបអង្កេត។ ប្រភេទនៃការសម្រេចចិត្តដែល APS ធ្វើគឺ៖

- មានភស្តុតាង៖ ទំនងជាឧប្បត្តិហេតុដែលត្រូវបានចោទប្រកាន់ថាបានកើតឡើង
- មិនមានភស្តុតាង៖ ទំនងជាឧប្បត្តិហេតុដែលត្រូវបានចោទប្រកាន់ថាមិនបានកើតឡើង
- មិនច្បាស់លាស់៖ មិនអាចកំណត់ថាតើឧប្បត្តិហេតុដែលត្រូវបានចោទប្រកាន់បានកើតឡើងឬអត់។

• ប្រសិនបើ APS រកឃើញថាវាទំនងជាឧប្បត្តិហេតុដែលបានកើតឡើង APS នឹងជូនដំណឹងដល់អ្នកដោយផ្ញើលិខិតមួយទៅអ្នកតាមរយៈសំបុត្រដែលមានការបញ្ជាក់ និងទៀងទាត់។

• ប្រសិនបើ APS រកឃើញថាវាទំនងជាឧប្បត្តិហេតុដែលមិនបានកើតឡើង APS នឹងជូនដំណឹងដល់អ្នកដោយផ្តាល់មាត់។ APS អាចផ្តល់លិខិតមួយដល់អ្នកប្រសិនបើអ្នកស្នើសុំ។

• អាចកំណត់ថាតើឧប្បត្តិហេតុបានកើតឡើងឬអត់ APS នឹងជូនដំណឹងដល់អ្នកដោយផ្តាល់មាត់។ APS អាចផ្តល់លិខិតមួយដល់អ្នកប្រសិនបើអ្នកស្នើសុំ។

• ប្រសិនបើ APS មិនមានអាសយដ្ឋានបច្ចុប្បន្នរបស់អកទេអ្នកអាចខកខានសំបុត្រសំខាន់ៗ និងថ្ងៃផុតកំណត់។

តើការរកឃើញភស្តុតាងមួយមានន័យដូចម្តេច?

ប្រសិនបើ APS សម្រេចថាការចោទប្រកាន់អំពីការរំលោភបំពាន ការធ្វេីប្រហែស ការបោះបង់ចោល ឬការកេញប្រវ័ញ្ចផ្នែកហិរញ្ញវត្ថុត្រូវបាន "ភស្តុតាងបញ្ជាក់" អ្នកអាចស្នើសុំសវនាការប្រសិនបើអ្នកមិនយល់ស្របនឹងការរកឃើញនេះ។ ប្រសិនបើការសម្រេចចិត្តរបស់ APS ត្រូវបានគាំទ្រនៅចុងបញ្ចប់នៃដំណើរការសវនាការ ឈ្មោះរបស់អ្នកនឹងត្រូវបានដាក់ចូលក្នុងបញ្ជីឈ្មោះ។

ការមានឈ្មោះនៅក្នុងបញ្ជីឈ្មោះមានន័យថាអ្នកប្រហែលមិនអាចធ្វេីការ ឬធ្វេីការងារស្ម័គ្រចិត្តនៅកន្លែងណាដែលអ្នកអាចមានទំនាក់ទំនងដោយគ្មានការត្រួតពិនិត្យជាមួយមនុស្សពេញវ័យ ឬកុមារដែលងាយរងគ្រោះនោះទ។ បច្ចុប្បន្ននេះមិនមានវិធីណាមួយដើម្បីដកឈ្មោះរបស់អ្នកចេញពីបញ្ជីនោះទេ។

តើខ្ញុំអាចជំទាស់ការសម្រេចចិត្តរបស់ **APS** បានដែរឬទេ?

• ប្រសិនបើ APS សម្រេចថាឧប្បត្តិហេតុដែលត្រូវបានចោទប្រកាន់គឺមិនមានភស្តុតាងបញ្ជាក់ ឬមិនមានការសន្និដ្ឋានច្បាស់លាស់ អ្នកមិនចាំបាច់ធ្វេីអ្វីទាំងអស់។

• ប្រសិនបើ APS សម្រេចថាឧប្បត្តិហេតុដែលត្រូវបានចោទប្រកាន់គឺមានភស្តុតាងបញ្ជាក់គ្រប់គ្រាន់ ហើយអ្នកមិនយល់ព្រមទេ អ្នកអាចស្នើសុំសវនាការ។ លិខិតរបស់ APS នឹងប្រាប់អ្នកពីរបៀប។

ដើម្បីស្នើសុំសវនាការ អ្នកមានពេលរហូតតែដល់ម៉ោង **5:00** ល្ងាច នៅថ្ងៃទី **30** នៃប្រតិទិន បន្ទាប់ពីថ្ងៃដែលលិខិតជូនដំណឹងរបស់ទាយកដ្ឋានត្រូវបានផ្ញើតាមអ៊ីមែល ឬប្រគល់ជូនអ្នកដោយផ្ទាល់ អាស្រ័យលើថារឿងមួយណាកើតឡើងមុន។

សម្រាប់ព័ត៌មានបន្ថែម

អ្នកអាចទទួលបានព័ត៌មានបន្ថែមអំពី APS តាមអ៊ីនធឺណិតនៅ

https://www.dshs.wa.gov/altsa/adult-protective-services-aps។